**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:......០៤..សសរ**

# សេចក្តីសំរេច

## ស្តីពី

## ការរៀបចំ «វេទិកាសំរាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី១»

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ខែកក្កដាឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១៤៧អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែមិនា ឆ្នាំ២០០៦ ស្តីពីការកែសំរួលមាត្រា១ នៃអនុក្រឹត្យលេខ១៤៧ អនក្រ.បក
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានទី១នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សំរេច

**ប្រការ ១ :-**

ប្រគល់ភារកិច្ចជូនឯកឧត្តម **គាត ឈន់** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានទី១នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការដឹកនាំ និងសំរបសំរួលការត្រៀមរៀបចំសំរាប់ **«វេទិកាសំរាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី១»** នាខែមិថុនាឆ្នាំ២០០៧ ខាងមុខនេះ ។

**ប្រការ ២ :-**

ក្នុងក្របខ័ណ្ឌនៃការដឹកនាំនិងសំរបសំរួលការត្រៀមរៀបចំសំរាប់វេទិកាលើកទី១នេះ ឯកឧត្តម **គាត ឈន់** ត្រូវសហការជាមួយប្រធាននៃបណ្តាក្រសួងនិងស្ថាប័នទាំងអស់នៃរាជរដ្ឋាភិបាល និងមានសិទ្ធិអញ្ជើញមន្ត្រីជាន់ខ្ពស់ ឱ្យចូលរួមប្រជុំអន្តរក្រសួង និងមានសិទ្ធិចាត់ចែងពិគ្រោះយោបល់ជាមួយនឹងបណ្តាដៃគូអភិវឌ្ឍន៍ទាំងអស់ ដើម្បីសំរបសំរួលការងារ និងដើម្បីរៀបចំសេចក្តីព្រាងឯកសារចាំបាច់នានា ។

**ប្រការ ៣ :-**

ឯកឧត្តម **គាត ឈន់** ត្រូវរាយការណ៍ជាបន្តបន្ទាប់ជូនសម្តេចនាយករដ្ឋមន្ត្រី អំពីវឌ្ឍនភាពនៃការរៀបចំវេទិកាលើកទី១ និងឯកសារចាំបាច់នានា ដើម្បីដាក់ជូនសម្តេចនាយករដ្ឋមន្ត្រីពិនិត្យ ផ្តល់អនុសាសន៍ និងអនុម័ត មុននឹងយកទៅប្រើប្រាស់ជាផ្លូវការ ។

**ប្រការ ៤ :-**

ក្នុងការបំពេញភារកិច្ចនេះ ឯកឧត្តម **គាត ឈន់** ប្រើប្រាស់ធនធានសម្ភារៈរបស់គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា (ក.អ.ក/គ.ជ.នា) ដែលមានឯកឧត្តម **ឈៀង យ៉ាណារ៉ា** ជាអគ្គលេខាធិការ សំរាប់ជំនួយការងារប្រចាំថ្ងៃ ។

**ប្រការ ៥ :-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ និងឯកឧត្តម **គាត ឈន់** ត្រូវអនុវត្តតាមសេចក្តីសំរេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ ៦ :-**

សេចក្តីសំរេចនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខារហូតដល់វេទិកាសំរាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី១បានប្រព្រឹត្តទៅចប់សព្វគ្រប់ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៧

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>កន្លែងទទួល</u>

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យ សម្តេច នាយករដ្ឋមន្ត្រី
- -ដូចប្រការ៥
- -ឯកសារ-កាលប្បវត្តិ